ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៤០...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# តំបន់ទេសចរណ៍ពិសេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១០/០០៦ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

អនុក្រឹត្យនេះ មានគោលបំណងជំរុញការអភិវឌ្ឍផលិតផលទេសចរណ៍ ទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិ និងជំរុញការវិនិយោគលើវិស័យទេសចរណ៍ ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា។

**មាត្រា២ ..**

អនុក្រឹត្យនេះ មានគោលដៅកំណត់វិធាននិងយន្តការក្នុងការបង្កើតនិងគ្រប់គ្រងតំបន់ទេសចរណ៍ពិសេស។

**មាត្រា៣ ..**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តលើតំបន់ទេសចរណ៍ពិសេសដែលត្រូវកំណត់ដោយរាជរដ្ឋាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ ..**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ មានន័យដូចខាងក្រោម៖

- **តំបន់ទេសចរណ៍ពិសេស** សំដៅដល់តំបន់ដែលមានសក្តានុពលទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល។ តំបន់ទេសចរណ៍ពិសេសនីមួយៗប្រមូលផ្តុំដោយសម្បទា និងសេវាកម្មទេសចរណ៍សំខាន់ៗ រួមមាន សេវាកម្មស្នាក់នៅ និវេសនដ្ឋានទេសចរណ៍ សេវាកម្មម្ហូបអាហារ និងភេសជ្ជៈ មណ្ឌលសម្រាកលំហែកម្សាន្តទេសចរណ៍ មណ្ឌលកីឡាទេសចរណ៍ សួន ឧទ្យាន មណ្ឌលផ្តល់សេវាថែទាំសុខភាពទេសចរណ៍ មណ្ឌលឬសេវាកម្មទេសចរណ៍ពាក់ព័ន្ធផ្សេងៗទៀត។
- **ម្ចាស់តំបន់ទេសចរណ៍ពិសេស ឬហៅថា ម្ចាស់តំបន់** សំដៅដល់បុគ្គលមានសញ្ជាតិខ្មែរឬបរទេសដែលបានទទួលគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យបង្កើត អភិវឌ្ឍ និងគ្រប់គ្រងតំបន់ទេសចរណ៍ពិសេសណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា។
- **ដៃគូតំបន់ទេសចរណ៍ពិសេស ឬហៅថា ដៃគូតំបន់** សំដៅដល់បុគ្គលសញ្ជាតិខ្មែរឬបរទេសដែលចូលរួមការអភិវឌ្ឍតំបន់ទេសចរណ៍ពិសេស ក្នុងនោះ រួមមានទេសចរពិសេសផងដែរ។
- **ទេសចរពិសេស** សំដៅដល់ទេសចរអន្តរជាតិដែលទទួលបានការអនុញ្ញាតចូល ចេញ និងស្នាក់នៅក្នុងតំបន់ទេសចរណ៍ពិសេស ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
- **បុគ្គល** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល។

## ជំពូកទី២
## លក្ខខណ្ឌនិងនីតិវិធីនៃការបង្កើតតំបន់ទេសចរណ៍ពិសេស

**មាត្រា៥ ..**

តំបន់ទេសចរណ៍ពិសេសត្រូវបានអនុញ្ញាតឱ្យបង្កើតឡើងនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជានៅតាមតំបន់សក្តានុពលទេសចរណ៍សមស្រប ប្រកបដោយយុទ្ធសាស្ត្រ ស្របតាមច្បាប់ជាធរមាននិងការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាដោយអនុក្រឹត្យ។

តំបន់ទេសចរណ៍ពិសេសអាចផ្តួចផ្តើមបង្កើតឡើងដោយរដ្ឋ ឬឯកជន ឬរដ្ឋចម្រុះឯកជន។ ការបង្កើតតំបន់ទេសចរណ៍ពិសេស ត្រូវអនុលោមទៅតាមលក្ខខណ្ឌដូចតទៅ៖

(ក) ត្រូវមានទំហំដីចាប់ពី១០០(មួយរយ)ហិកតាឡើងទៅ ដោយត្រូវមានទីតាំងព្រំប្រទល់ភូមិសាស្ត្រនិងនិយាមកាច្បាស់លាស់។

(ខ) ត្រូវមានផែនការមេអភិវឌ្ឍន៍តំបន់ទេសចរណ៍ពិសេស។

(គ) ត្រូវមានសម្បទា សេវាកម្មទេសចរណ៍ដូចជា សេវាកម្មស្នាក់នៅទេសចរណ៍ និវេសនដ្ឋានទេសចរណ៍ សេវាកម្មម្ហូបអាហារនិងភេសជ្ជៈ សេវាកម្ម មណ្ឌលកម្សាន្តទេសចរណ៍ មណ្ឌលសម្រាកលំហែកម្សាន្តទេសចរណ៍ មណ្ឌលកីឡាទេសចរណ៍ មណ្ឌលពាណិជ្ជកម្ម មណ្ឌលផ្តល់សេវាថែទាំសុខភាពទេសចរណ៍ មណ្ឌលឬសេវាកម្មទេសចរណ៍ពាក់ព័ន្ធផ្សេងៗទៀតជាដើម។

(ឃ) ត្រូវមានហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា ដូចជា ប្រព័ន្ធផ្លូវគមនាគមន៍ ប្រព័ន្ធទឹកស្អាត អគ្គិសនី បណ្តាញប្រៃសណីយ៍ ទូរគមនាគមន៍ ប្រព័ន្ធប្រព្រឹត្តិកម្មសម្អាតសំណល់រាវនិងការគ្រប់គ្រងសំណល់រឹងត្រឹមត្រូវ មានវិធានការពារបរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធដទៃទៀតជាដើម។

(ង) ត្រូវមានម្ចាស់តំបន់និង/ឬដៃគូតំបន់ចូលរួមការអភិវឌ្ឍក្នុងតំបន់ទេសចរណ៍ពិសេស។

**មាត្រា៦ ..**

បុគ្គលទាំងឡាយដែលមានបំណងបង្កើតតំបន់ទេសចរណ៍ពិសេសនៅក្នុងតំបន់សក្តានុពលទេសចរណ៍ណាមួយ ត្រូវធ្វើសំណើសុំគោលការណ៍អនុញ្ញាតឱ្យបង្កើតនិងអភិវឌ្ឍតំបន់ទេសចរណ៍ពិសេសពីរាជរដ្ឋាភិបាលតាមរយៈគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ដែលជាសេនាធិការ។ គណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍មានភារកិច្ចធ្វើការសិក្សា វាយតម្លៃ និងសន្និដ្ឋានលើសំណើសុំ ហើយលើកយោបល់ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យសម្រេច។

**មាត្រា៧ ..**

ម្ចាស់តំបន់ដែលបានទទួលគោលការណ៍អនុញ្ញាតឱ្យបង្កើតនិងអភិវឌ្ឍតំបន់ទេសចរណ៍ពិសេសពីរាជរដ្ឋាភិបាលមានរយៈពេលចំនួន១៨០(មួយរយប៉ែតសិប)ថ្ងៃ ដើម្បីធ្វើគម្រោងសិក្សាពីសមិទ្ធិលទ្ធភាពទេសចរណ៍ ដែលរួមមានការបង្ហាញផែនការមេអភិវឌ្ឍន៍ គម្រោងហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានាក្នុងតំបន់ទេសចរណ៍ពិសេស ដាក់ជូនគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍។ ម្ចាស់តំបន់អាចស្នើសុំពន្យាររយៈពេលកំណត់នេះបានមិនលើសពី៩០(កៅសិប)ថ្ងៃ ក្នុងករណីមានមូលហេតុច្បាស់លាស់។

**មាត្រា៨ ..**

គោលការណ៍អនុញ្ញាតឲ្យបង្កើតនិងអភិវឌ្ឍតំបន់ទេសចរណ៍ពិសេស អាចនឹងត្រូវលុបចោល ក្នុងករណីដែលម្ចាស់តំបន់មិនបានអនុវត្តតាមផែនការមេអភិវឌ្ឍន៍ឬកិច្ចសន្យានានា។

**មាត្រា៩ ..**

ម្ចាស់តំបន់ធ្វើសកម្មភាពស្ថិតនៅក្រោមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ម្ចាស់តំបន់៖

(ក) ត្រូវមានសិទ្ធិស្របច្បាប់លើដីដែលស្នើសុំបង្កើតតំបន់ទេសចរណ៍ពិសិដ្ឋ។

(ខ) ត្រូវមានធនធាននិងមធ្យោបាយគ្រប់គ្រាន់ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សម្បទាពាក់ព័ន្ធនឹងទេសចរណ៍នានាក្នុងតំបន់ រួមទាំងធនធានមនុស្សដើម្បីដឹកនាំឬប្រតិបត្តិសកម្មភាពនៃតំបន់។

(គ) ធ្វើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រនៅក្នុងតំបន់ រួមមាន ការសាងសង់ប្រព័ន្ធអគ្គិសនី ប្រព័ន្ធសម្អាតកាកសំណល់រឹងនិងរាវ ប្រព័ន្ធទឹកស្អាត ប្រព័ន្ធផ្លូវគមនាគមន៍ ប្រព័ន្ធទូរគមនាគមន៍ សម្បទានានានៃតំបន់ទេសចរណ៍ពិសិដ្ឋ ប្រព័ន្ធថែរក្សានិងគ្រប់គ្រងរួមនៃតំបន់ រៀបចំសម្បទា និងសេវាកម្មផ្សេងៗទៀត ដែលជាតម្រូវការចាំបាច់នៅក្នុងតំបន់។

(ឃ) ត្រូវមានសកម្មភាពអាជីវកម្មពាណិជ្ជកម្ម និងការផ្តល់សេវាកម្មទេសចរណ៍នានា។

(ង) ធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់នៅក្នុងតំបន់ជាប្រចាំ។

(ច) ធ្វើការផ្សព្វផ្សាយនិងផ្តល់ព័ត៌មានអំពីតំបន់ទេសចរណ៍ពិសិដ្ឋ ដើម្បីទាក់ទាញការចូលរួមអភិវឌ្ឍ។

(ឆ) ធ្វើការថែទាំនិងជួសជុលហេដ្ឋារចនាសម្ព័ន្ធធានាបាននូវគុណភាពនិងអនាម័យត្រឹមត្រូវ និងទទួលខុសត្រូវចំពោះមុខច្បាប់លើរាល់សកម្មភាពមិនប្រក្រតីនិងការអនុវត្តខុសពីគោលការណ៍របស់រាជរដ្ឋាភិបាល។

(ជ) ត្រូវគោរពនិងអនុវត្តតាមច្បាប់ស្តីពីវិនិយោគ និង ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

(ឈ) ធ្វើរបាយការណ៍ជូនគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍និងស្ថាប័នពាក់ព័ន្ធនានាតាមការកំណត់។

(ញ) សហការក្នុងកិច្ចដំណើរការអភិវឌ្ឍតំបន់ និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋានជាពិសេសគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍រាជធានីខេត្ត ដើម្បីដោះស្រាយការងារដែលមានការពាក់ព័ន្ធ។

## ជំពូកទី៣
## យន្តការសម្របសម្រួលគ្រប់គ្រងតំបន់ទេសចរណ៍ពិសិដ្ឋ

**មាត្រា១០.-**

គណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ ជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការសម្របសម្រួល ជំរុញការអភិវឌ្ឍ ការអនុវត្ត និងគ្រប់គ្រងតំបន់ទេសចរណ៍ពិសិដ្ឋ ៖

(១) រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ លើកគម្រោងផែនការ និងកំណត់ទិសដៅសម្រាប់ការអភិវឌ្ឍនិងគ្រប់គ្រងតំបន់ទេសចរណ៍ពិសិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

(២) ពិនិត្យ វាយតម្លៃ សន្និដ្ឋាន និងផ្តល់យោបល់លើសំណើសុំគោលការណ៍អនុញ្ញាតបង្កើតនិងអភិវឌ្ឍតំបន់ទេសចរណ៍ពិសិដ្ឋ និងលើកសំណើជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យសម្រេច។

(៣) ពិនិត្យនិងសម្រេចលើគម្រោងសិក្សាពីសមិទ្ធិលទ្ធភាពទេសចរណ៍។

(៤) លើកសំណើជូនរាជរដ្ឋាភិបាលដើម្បីលុបចោលគោលការណ៍អនុញ្ញាតឱ្យបង្កើតនិងអភិវឌ្ឍតំបន់ទេសចរណ៍ពិសិដ្ឋ។

(៥) កំណត់គោលការណ៍ បទប្បញ្ញត្តិទាំងឡាយ និងស្តង់ដាដែលពាក់ព័ន្ធដល់ការគ្រប់គ្រងតំបន់ទេសចរណ៍ពិសិដ្ឋ សហការសម្របសម្រួល ដោះស្រាយសំណូមពរនិងបញ្ហានានា។

(៦) សម្របសម្រួលការអនុវត្ត ការលើកទឹកចិត្តនានាដល់ម្ចាស់តំបន់ ដៃគូតំបន់ ឬទេសចរពិសេស នៃតំបន់ទេសចរណ៍ពិសិដ្ឋស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

(៧) រៀបចំគោលការណ៍ណែនាំអំពីការងារគ្រប់គ្រង អភិវឌ្ឍការងារពាក់ព័ន្ធផ្សេងៗ ការបង្កលក្ខណៈងាយស្រួលក្នុងកិច្ចទំនាក់ទំនងជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលដើម្បីធានាឱ្យកិច្ចការរបស់តំបន់ទេសចរណ៍ពិសិដ្ឋប្រព្រឹត្តទៅមានភាពលូននិងមានប្រសិទ្ធភាព។

គណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍មានលេខាធិការដ្ឋាននៅទីស្តីការក្រសួងទេសចរណ៍ និងត្រូវមានក្រុមការងារមួយទទួលបន្ទុកកិច្ចការតំបន់ទេសចរណ៍ពិសិដ្ឋនេះ។ ភារកិច្ចនិងសមាសភាពជាក់ស្តែងនៃក្រុមការងារតំបន់ទេសចរណ៍ពិសិដ្ឋ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍។

គណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍នេះមានយន្តការថ្នាក់ក្រោមជាតិជាសេនាធិការ គឺគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍រាជធានីខេត្ត។

## ជំពូកទី៤
## ការទទួលបានការលើកទឹកចិត្ត

**មាត្រា១១ ..**

ការលើកទឹកចិត្តនានាក្នុងតំបន់ទេសចរណ៍ពិសិដ្ឋ ត្រូវអនុវត្តតាមច្បាប់ស្តីពីវិនិយោគ និង ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននានានៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១២ ..**

ម្ចាស់តំបន់ ដៃគូតំបន់ ឬទេសចរពិសេសអាចទទួលបានការលើកទឹកចិត្តផ្សេងៗទៀតដូចជា៖

- អាចទទួលបានទិដ្ឋាការចេញចូលកម្ពុជាច្រើនដង ឬការលើកលែងទិដ្ឋាការ និងស្នាក់នៅរយៈពេលយូរស្របតាមច្បាប់កំណត់ ឬអាចប្រើប្រាស់បណ្ណអនុញ្ញាតចេញចូលពិសេសពីរាជរដ្ឋាភិបាល។
- អាចទទួលបានសិទ្ធិកម្មសិទ្ធិឬសិទ្ធិប្រើប្រាស់អាស្រ័យផលលើអចលនទ្រព្យនៅក្នុងតំបន់ទេសចរណ៍ពិសិដ្ឋស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៥
## ភារកិច្ចរបស់
## ម្ចាស់តំបន់ ដៃគូតំបន់ និងទេសចរពិសេសក្នុងតំបន់ទេសចរណ៍ពិសិដ្ឋ

**មាត្រា១៣ ..**

ម្ចាស់តំបន់ ដៃគូតំបន់ និងទេសចរពិសេសក្នុងតំបន់ទេសចរណ៍ពិសិដ្ឋ ត្រូវមានភារកិច្ចដូចខាងក្រោម៖

- គោរពច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- គោរពប្រពៃណីទំនៀមទម្លាប់ល្អនិងវប្បធម៌ជាតិ
- ត្រូវចូលរួមជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា

- មិនធ្វើឲ្យខូចខាតប៉ះពាល់បរិស្ថាន មរតកវប្បធម៌ប្រវត្តិសាស្ត្រ និងធនធានធម្មជាតិ
- មិនចូលរួមក្នុងសកម្មភាពណាដែលធ្វើឲ្យប៉ះពាល់អវិជ្ជមានដល់នយោបាយ សន្តិភាព សន្តិសុខ ស្ថិរភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។

**ជំពូកទី៦**
**អវសានប្បញ្ញត្តិ**

**មាត្រា១៤ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ..២កើត ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ... ខែ មីនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ថោង ខុន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ